*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**
លេខ ៨៤៧ "ធ"
ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៩
សំណុំរឿងរដ្ឋប្បវេណី
លេខ ២៦៦៧
ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៨

# ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ នៅសាលាដំបូងរាជធានីភ្នំពេញ លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៦៧ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក **សេង លាង** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ជាម ផនវិច្ឆិកា** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទ ក្រុមហ៊ុន **ដ** មានអាសយដ្ឋានស្នាក់ការកណ្ដាល ប្រទេសវៀតណាម តំណាងដោយឈ្មោះ **ត១ដ** និងលោក **ត២ដ** ។

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ លោក **ឈរ ស៊ុនហុង** លោក **ខុម ឌីណា** និងលោក **អ៊ិន ឌីណា** មានការិយាល័យនៅអាគារផ្សារទំនើបបាយ័ន ជាន់ទី៤ យូនីត ៤០៨-៤៨ មហាវិថី Jok Dimitrov សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-និងចុងចម្លើយឈ្មោះ **ប** ក្រុមហ៊ុន ចុះបញ្ជីក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា មានអាសយដ្ឋាននៅរាជធានីភ្នំពេញ តំណាងដោយលោក **តង** ។

មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ លោក **ប៊ុន កែវលីម** មានការិយាល័យនៅផ្ទះលេខបេ២៨ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

## I. **អង្គហេតុនិងចំណុចវិវាទ**

### ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១-១/ បង្គាប់ឱ្យចុងចម្លើយ ក្រុមហ៊ុន **ប** សងប្រាក់ដើមសរុបចំនួន ២១៣,៥៣៥USD(ម្ភៃមួយម៉ឺនបីពាន់ប្រាំរយសាមសិបប្រាំដុល្លារអាមេរិក)។

១-២/ សុំឱ្យចុងចម្លើយបង់ការប្រាក់តាមច្បាប់កំណត់នៃប្រាក់សរុបចំនួន ២១៣,៥៣៥USD(ម្ភៃមួយម៉ឺនបីពាន់ប្រាំរយសាមសិបប្រាំដុល្លារអាមេរិក)។

១-៣/ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២ភាគរយក្នុង១ខែ នៃប្រាក់សរុបគិតចាប់ពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

១-៤/ បង្គាប់ឱ្យចុងចម្លើយសងថ្លៃសេវាមេធាវី និងការខាតបង់នានាពីការប្ដឹងផ្ដល់នេះជាប្រាក់ ចំនួន ២០,០០០(ពីរម៉ឺន)ដុល្លារអាមេរិក ឱ្យដើមចោទ។

១-៥/ ឱ្យចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី ។

១-៦/ សុំប្រកាសឱ្យអនុវត្តសាលក្រមជាបណ្ដោះអាសន្នត្រង់ចំណុចទី១-១ ។

កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

**២. ការពន្យល់ត្រួសៗអំពីរឿងក្តី៖** ក្នុងរឿងក្តីនេះដើមចោទសុំទាមទារដូចក្នុងចំណុចទី១ខាងលើ ដោយហេតុថា នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ក្រុមហ៊ុន ជ និង ប បានចុះកិច្ចព្រមព្រៀងទិញលក់សម្ភារៈសំណង់ ក្នុងគម្រោងរោងចក្រ ●១ មានទីតាំងនៅក្រុងតំបន់សេដ្ឋកិច្ចពិសេស ក្នុង ខេត្តបន្ទាយមានជ័យ ដែលមានតម្លៃទឹកប្រាក់ ៦៥០,០០០ដុល្លារអាមេរិក ហើយត្រូវទូទាត់ប្រាក់ទៅតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យានោះ។ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៦ ក្រុមហ៊ុនដើមចោទ បានធ្វើលិខិតជូនដំណឹងបញ្ជាក់ពីការងារចប់សព្វគ្រប់ និងប្រគល់ទំនិញ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៦ បន្ទាប់ពីក្រុមហ៊ុនចុងចម្លើយ បានបំពេញកាតព្វកិច្ចយ៉ាងត្រឹមត្រូវនិងពេញលេញ។ ក្រោយមកទៀតក្រុមហ៊ុនចុងចម្លើយបានទូទាត់ថ្លៃទិញលក់នេះតែមួយចំនួនប៉ុណ្ណោះ នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៨ ចុងចម្លើយបានទូទាត់ប្រាក់បន្ថែមចំនួន ៧៥០០០ដុល្លារអាមេរិក នៅសល់ប្រាក់ចំនួន ២១៣៥៣៥ដុល្លារអាមេរិកទៀត។

**៣. អង្គហេតុដែលអះអាងដោយភាគី**

-លោក **ឈរ ស៊ិនហុង** មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថ្លែងការណ៍ថា ៖ ខ្ញុំបាទសុំរក្សាសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៩ ទុកដដែល។ ខ្ញុំបាទសុំសង្ខេបអង្គហេតុដូចតទៅ៖ កូនក្តីខ្ញុំ និងចុងចម្លើយបានចុះកិច្ចសន្យាថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ កិច្ចសន្យាទិញលក់សំណង់ក្នុងគម្រោងរោងចក្រ ●១ ដែលមានតម្លៃទឹកប្រាក់សរុប ៦៥ម៉ឺនដុល្លារ។បន្ទាប់មកចុងចម្លើយបានទិញសម្ភារៈបន្ថែម នៅថ្ងៃទី ១៥ សីហា ឆ្នាំ ២០១៦។ បន្ទាប់មកកូនក្តីខ្លួនបានបញ្ចប់ភារកិច្ចរបស់ខ្លួន នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ និងបានប្រគល់ជូនពេញ លេញឱ្យចុងចម្លើយ ដោយមានឯកសារលេខ ចុងចម្លើយក៏ព្រមទទួលយកដែរ។ ស្របពេលនោះដែរភាគីចុងចម្លើយត្រូវប្រគល់ប្រាក់ចំនួនមកឱ្យដើមចោទ តែមិនព្រមប្រគល់ឱ្យ។ ហើយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ ភាគីទាំង២ព្រមព្រៀងគ្នាលើទឹកប្រាក់ចំនួន ២៨៨,៥៣៥ដុល្លារ ដោយ ចុងចម្លើយត្រូវបង់ ជា២ដំណាក់កាល ទី២ បង់ប្រាក់ដែលនៅសល់ ១៣ម៉ឺនដុល្លារ(មិនបានកំណត់ថ្ងៃទេ)។ នៅថ្ងៃទី ចុងចម្លើយបានបង់ប្រាក់ចំនួន ៧៥០០០ដុល្លារ ដូចមានក្នុងពាក្យសុំផ្ទេរប្រាក់ក្រៅប្រទេស ដូច្នេះនៅសល់ប្រាក់ ២១៣៥៣៥ដុល្លារមិនទាន់បង់ ក្រោយមកចុងចម្លើយឈប់បង់រហូតទល់ពេលនេះ។ សំណូមពរ១/ សុំតុលាការសម្រេចប្រាក់ដើមចំនួន ២១៣,៥៣៥ដុល្លារ ២/ បង់ការប្រាក់តាមច្បាប់ ១៨% គិតពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ ៣/ និងប្រាក់ពិន័យ ២%ក្នុងមួយខែ លើប្រាក់ដើមផ្អែកតាមកិច្ចសន្យា ៤/ សេវាកម្មមេធាវី និងជំងឺចិត្ត ២ម៉ឺនដុល្លារអាមេរិក ៥/ សុំប្រកាសជាបណ្តោះអាសន្នលើចំណុចទី១ ខាងលើ ៦/ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

-លោក **ប៊ុន កែវលឹម** មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថ្លែងការណ៍ថា ៖ ខ្ញុំបាទសុំច្រានចោលបណ្តឹងទាមទាររបស់ដើមចោទខាងលើទាំងស្រុង។ អង្គហេតុខាងលើ កូនក្តីខ្ញុំបាទពិតជាបានចុះកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ មែន។ កូនក្តីខ្ញុំបាទ និងដើមចោទបានបំពេញការងារសហការជាមួយគ្នាច្រើនសារមកហើយ ហើយមានភាពរលូនទៀត។ ចំពោះទឹកប្រាក់ ២១៣,៥៣៥ដុល្លារ កូនក្តីខ្ញុំបាទរង់ចាំដើមចោទធ្វើការទូទាត់ ដោយកន្លងមកដើមចោទបានឱ្យក្រុមហ៊ុនផ្សេងធ្វើបន្ត តែគាត់ឱ្យក្រុមហ៊ុនផ្សេងធ្វើ កូនក្តីខ្ញុំបាទបានទុកចិត្តលើក្រុមហ៊ុនដើមចោទ។ ការទទួលនៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ គឺជាការទទួលបណ្តោះអាសន្នទេ គឺមានការធានារយៈពេល ១ឆ្នាំ តែដំបូលនោះមានការលេច ផ្ទុះធ្លាយធ្វើឱ្យកូនក្តីខ្ញុំបាទមានការខាតបង់ជាមួយក្រុមហ៊ុន ●១ ។ កូនក្តីខ្ញុំបានឱ្យដើមចោទជួយបំពេញបន្ថែមលើការជួសជុលដំបូល តែគាត់មិនធ្វើឱ្យទេ ទើបកូនក្តីខ្ញុំបាទជួលក្រុមហ៊ុនថ្មីមកធ្វើការជួសជុលវិញដើម្បីកុំឱ្យមានការប៉ះពាល់ដល់ម៉ាស៊ីន និង ការងារសម្ភារៈផ្សេងៗក្នុងក្រុមហ៊ុន ●១ ដោយម៉ាស៊ីនគេមានតម្លៃ។ ក្នុងអំឡុងពេល ២០១៧ កូនក្តីខ្ញុំបាទបានជួលជាង មកជួសជុល ជួលប៉ុន្មានដង ខ្ញុំបានមិនចាំទេ។ ក្រោយមកភាគីដើមចោទមកចរចារជាមួយកូនក្តីខ្ញុំបាទ នៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ ព្រមព្រៀងថាកូនក្តីខ្ញុំបាទព្រមទូទាត់ទឹកប្រាក់ ២១៣៥៣៥ដុល្លារ តែភាគីដើមចោទត្រូវពិនិត្យទូទាត់លើដំបូលនិងធ្វើការជំរះបញ្ជី។ តែដើមចោទមិនបានបំពេញទេ ហើយនៅតែទាមទារប្រាក់ខាងលើដដែល កូនក្តីខ្ញុំបាទទទួលមិនបាននោះទេ។ មួយទៀតការអនុវត្តបណ្តោះអាសន្នលើ

ប្រាក់ដើម សុំតុលាការពិនិត្យលើឲ្យសនកម្មលើកូនក្តីខ្ញុំបាទ មិនទាន់មានការទូទាត់ជំរះបញ្ជីគ្នា ខ្ញុំបាទមានឯកសារបញ្ជាក់អំពីការជួលជាងជួសជុល និងខ្ញុំបាទសុំបញ្ចូលសេចក្តីថ្លែងការណ៍បន្ថែមនៅពេលក្រោយ។

-មេធាវីដើមចោទតបថា៖ សុំតុលាការពិនិត្យមើលឯកសារ ការប្រគល់ការងារនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៦ គឺជាការប្រគល់ការងារពេញលេញ មិនមែនបណ្តោះអាសន្នទេ។ ជាក់ស្តែងកូនក្តីខ្ញុំបាទទទួលបានប្រាក់តែ ៣០%ទេនៃប្រាក់សរុប កូនក្តីខ្ញុំបាទទារគាត់រហូត រហូតដល់ឆ្នាំ ២០១៧ គាត់បានសងខ្លះ សរុបទាំងអស់ប្រាក់ជំពាក់នៅសល់ចំនួន ២៨៨៥៣៥ដុល្លារអាមេរិក។ សុំបញ្ជាក់ថា ក្នុងកំណត់ហេតុថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ប្រសិនបើបង់ប្រាក់ចំនួន ១៥៨៥៣៥ដុល្លារ នឹងចេញលិខិតធានាស្តង់ដាការងាររបស់កូនក្តីខ្ញុំគឺត្រឹមត្រូវ ទី២ ប្រសិនបង់ប្រាក់ចំនួន ១៣ម៉ឺនដុល្លារ នឹងជួសជុលកន្លែងណាលិចធ្លុះធ្លាយ។ តែចុងចម្លើយបង់តែ ៧៥០០០ដុល្លារ នៅសល់ ២១៣៥៣៥ដុល្លារ ហើយខាងចុងចម្លើយឈប់បង់រហូតដល់ពេលនេះ កូនក្តីខ្ញុំបាទតែងតែទៅមើលការដ្ឋាន (ទៅពីរដង) នៅខេត្តបន្ទាយមានជ័យ។

-ដើមចោទថា៖ ពេលទៅពិនិត្យ បានវាយតម្លៃជួសជុលកន្លែងខូចខាតអស់ប៉ុន្មានទៅ ●១ តែខាង ●១ (ចុងចម្លើយ)អត់មានឆ្លើយតបអ្វីមកវិញទេ។

-មេធាវីចុងចម្លើយតបថា៖ ពាក់ព័ន្ធនឹងការចរចារនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ កូនក្តីខ្ញុំបាទមិនបានបង់ប្រាក់ ព្រោះមានការបារម្ភ។ ពេលកូនក្តីខ្ញុំបាទប្រគល់ប្រាក់ ៧៥០០០ដុល្លារ រួច ដើមចោទមិនបានដាក់ជាងមកពិនិត្យជួសជុលទេ។ ចំណុចបង់ប្រាក់២ដំណាក់កាលគឺមានក្នុងកិច្ចព្រមព្រៀងខាងលើមែន តែតាមការចរចារគ្នាក្រៅ ខាងដើមចោទក៏ព្រមដែរថា ពេលទូទាត់ កូនក្តីខ្ញុំបាទឲ្យលុយជាដំណាក់កាល១។ កូនក្តីខ្ញុំបាទបានបញ្ជាក់ថាពុំឃើញមានភាគីដើមចោទចុះទៅទេ។ ខ្ញុំបាទជាមេធាវីមិនបានដឹងច្បាស់រឿងដើមចោទចុះទៅ២ដងទេ ហើយខាងដើមចោទដាក់សំណើវាយតម្លៃការជួសជុលទៅ ខាង ●១ ឬអត់ទេ?

-ដើមចោទថា៖ សំណើវាយតម្លៃ គឺនិយាយផ្ទាល់មាត់ អត់មានឯកសារទេ។ ខ្ញុំបាទមិនចាំថ្ងៃណាបានចុះទៅទេ ខ្ញុំចាំថាខ្ញុំបាទទៅជាមួយមេខ្ញុំ ●២ ឈ្មោះ ●៣ ជួបពេលរសៀល ។ ចំពោះសែក ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១៧ តែសែកនេះអត់មានលុយទេ សែកនេះសរសេរទឹកប្រាក់ចំនួន ២៨៥៣៥ដុល្លារអាមេរិក តែដូចជាថ្លៃទូទាត់ទិញសម្ភារៈទេ។

-មេធាវីចុងចម្លើយ៖ ខ្ញុំបាទសុំបញ្ជាក់ថា ចំពោះសែកនេះគឺបានព្រមព្រៀងបានបញ្ចូលក្នុងថ្ងៃ ២៤ ខែមករា ឆ្នាំ ២០១៨ រួចហើយ។

-ដើមចោទថា៖ ខ្ញុំឯកភាពថាវាចូលក្នុងកំណត់ហេតុព្រមព្រៀងខាងលើ តែគ្រាន់តែចង់បញ្ជាក់ប៉ុណ្ណោះ។

-មេធាវីចុងចម្លើយថា៖ កូនក្តីខ្ញុំនៅតែសុំឲ្យដើមចោទទូទាត់ឲ្យត្រឹមត្រូវជាមួយកូនក្តីខ្ញុំ ខ្ញុំបាទមិនដឹងថាអស់ទឹកប្រាក់ប៉ុន្មានទេ តែដើមចោទនៅតែមិនទទួលយក។

-មេធាវីដើមចោទថា៖ ការចរចារនេះតាំង ២០១៦ ២០១៧មក តែចុងចម្លើយអត់បង្ហាញពត៌មាននេះទេ ខាងកូនក្តីខ្ញុំបាទទៅមើលហើយគាត់អត់ដាក់អ្នកបច្ចេកទេស ដាក់ជាងធម្មតា សុំឲ្យមានចរចារគ្នារហូត អូសបន្លាយពេលវេលារហូត។

-មេធាវីចុងចម្លើយថា៖ ការលិចធ្លុះធ្លាយ បានស្នើសុំដើមចោទដែរ តែគាត់មិនដាក់ជាងមក កូនក្តីខ្ញុំត្រូវរកជាងថ្មីជួសជុលបន្ទាន់ មិនអាចរង់ចាំគាត់បន្តបានទេ ព្រោះក្រុមហ៊ុនដែល កូនក្តីខ្ញុំទទួលការសាងសង់គេរករឿង។

-មេធាវីដើមចោទថា៖ ភាគីចុងចម្លើយស្នើសុំភ្នាម ធ្វើភ្នាម តែភាគីខ្ញុំស្នើសុំចុងចម្លើយបង់ប្រាក់សិន ព្រោះគាត់បង់បានតែ ៣០%ដំបូង។ ហើយការប្រគល់ការងារតាំងពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦មក គឺមិនដែលមានបញ្ហាទេហើយ គាត់ក៏មិនបង់ប្រាក់មកខាងខ្ញុំរហូតមក។

-មេធាវីចុងចម្លើយ៖ ក្រុមហ៊ុន ●១ ស្នើមកកូនក្តីខ្ញុំដែរ បើមានទឹកស្រកតែបន្តិចក៏ប៉ះពាល់ដល់ម៉ាស៊ីនក្រុមហ៊ុនគេដែរ។

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

៤. ចំណុចវិវាទ ៖ តើចុងចម្លើយពិតជាបានព្រមព្រៀងបង់ប្រាក់ចំនួន ២៨៨,៥៣៥ដុល្លារអាមេរិកឲ្យដើមចោទដែរឬទេ?

## II. ភស្តុតាងឯកសារពិនិត្យ

### ក/ ឯកសារភស្តុតាងដាក់ដោយដើមចោទ៖

-កិច្ចសន្យាលេខ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦

-កិច្ចព្រមព្រៀងក្នុងកិច្ចសន្យាលេខ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៦

-សំណើសុំត្រួតពិនិត្យ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦

-វិញ្ញាបនបត្របញ្ជាក់ពីការបញ្ចប់ការងារ និងការប្រគល់ជូនពេញលេញ ចុះថ្ងៃទី ១៤-៩-២០១៦

-មូលប្បទានបត្រ បញ្ជូនត្រឡប់ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១៧

-លិខិតសុំទូទាត់ប្រាក់នៅសល់សម្រាប់គម្រោង ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០១៧

-លិខិតរបស់ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០១៧

-លិខិតដាស់តឿន ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៨

-កំណត់ហេតុកិច្ចប្រជុំ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨

-ពាក្យស្នើសុំផ្ទេរប្រាក់ក្រៅប្រទេស ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៨

-វិក័យបត្រអាករលេខ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១៦

-គម្រោងរោងចក្រ [redacted] ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៦

-របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន [redacted] ។

### ខ/ ភស្តុតាងដាក់ដោយចុងចម្លើយ៖

-ឯកសាររូបថតខ្ទចខាតដំបូលចំនួន ៣៣សន្លឹក

-និងលិខិតបញ្ជាក់ការទូទាត់ប្រាក់ទៅក្រុមហ៊ុនដើមចោទ ចំនួន ៧៥០០០ដុល្លារ ចុះថ្ងៃទី ១២-៣-២០១៨

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងឯកសារក្នុងសំណុំរឿង និងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ ឃើញថា ៖

១-តាមការអះអាងរបស់ភាគីដើមចោទ និងតាមរយៈកិច្ចសន្យា ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ខាងលើរវាងភាគីដើមចោទ និងចុងចម្លើយ តុលាការទទួលស្គាល់ថាចុងចម្លើយក្រុមហ៊ុន [redacted] ដែលមានតំណាងដោយឈ្មោះ [redacted] និងដើមចោទ ពិតជាបានធ្វើការព្រមព្រៀងគ្នាចុះកិច្ចសន្យា ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ ការទិញលក់សំណង់ក្នុងគម្រោងរោងចក្រ [redacted] ក្នុងតម្លៃទឹកប្រាក់សរុប ៦៥០,០០០ដុល្លារអាមេរិកពិតប្រាកដមែន ហើយក្រោយមកដើមចោទបានបញ្ចប់ភារកិច្ចរបស់ខ្លួន នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ និងបានប្រគល់ជូនពេញលេញឲ្យចុងចម្លើយរួចហើយ។ ក្រោយពីចុងចម្លើយទទួលយករួចហើយ គឺមិនបានបង់ប្រាក់ឲ្យដើមចោទនៅឡើយទេ ដោយខ្លួនបានស្នើសុំទូទាត់ប្រាក់មកដើមចោទជាដំណាក់កាល តែចុងចម្លើយនៅតែមិនបានបង់ដដែល ទោះបីជាដើមចោទបានធ្វើលិខិតដាស់តឿនចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៨ ទៅចុងចម្លើយក៏ដោយ។ ក្នុងអង្គហេតុខាងលើនេះចុងចម្លើយក៏បានទទួលស្គាល់ដែរ ផ្អែកតាមឯកសារភស្តុតាងដាក់ដោយដើមចោទខាងលើ។ ក្រោយមកទៀតនៅថ្ងៃទី២៤ ខែមករា ឆ្នាំ ២០១៨ ភាគីទាំងពីរបានព្រមព្រៀងគ្នាលើទឹកប្រាក់ចំនួន ២៨៨,៥៣៥ដុល្លារអាមេរិក ដែលតម្រូវឲ្យចុងចម្លើយបង់។ តាមការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបញ្ជាក់ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បានទទួលស្គាល់ហើយថាទឹកប្រាក់ ២៨៨,៥៣៥ដុល្លារអាមេរិកពិតជាបានព្រមព្រៀងតាមកំណត់ហេតុប្រជុំ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ ពិតមែន ដូច្នេះតុលាការទទួលស្គាល់ថា/

ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាលើទឹកប្រាក់ចំនួន ២៨៨,៥៣៥ដុល្លារអាមេរិក ដែលតម្រូវឱ្យចុងចម្លើយបង់ឱ្យដើមចោទ ផ្អែកតាមកំណត់ហេតុនៃកិច្ចប្រជុំ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨។

២-ដោយឡែកនៅថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៨ ចុងចម្លើយបានបង់តែចំនួន ៧៥,០០០ដុល្លារអាមេរិកប៉ុណ្ណោះឱ្យដើមចោទ នៅសល់ចំនួន ២១៣,៥៣៥ដុល្លារអាមេរិកទៀត ចុងចម្លើយមិនបានបង់តាមកំណត់ហេតុនៃកិច្ចប្រជុំ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ ឡើយ។ មេធាវីចុងចម្លើយអះអាងថា ចំពោះទឹកប្រាក់ ២១៣,៥៣៥ដុល្លារអាមេរិក កូនក្ដីខ្លួននៅរង់ចាំដើមចោទធ្វើការទូទាត់ការជួសជុលដំបូល និងការជំរះបញ្ជីជាមុនសិន ទើបបង់ប្រាក់នេះឱ្យដើមចោទ។ ចំណុចនេះមេធាវីដើមចោទក៏បញ្ជាក់ដែរថា តាមកំណត់ហេតុព្រមព្រៀង ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៨ គូភាគីព្រមព្រៀងថាចុងចម្លើយត្រូវបង់ប្រាក់ជា២ដំណាក់កាល ដំណាក់កាលទី១ បង់ចំនួន ១៥៨,៥៣៥ដុល្លារអាមេរិក ដើមចោទត្រូវចេញលិខិតធានា បង់ដំណាក់កាលទី២ ចំនួន ១៣០,០០០ដុល្លារអាមេរិក នៅពេលដែលដើមចោទជួសជុលកន្លែងទឹកលេចនៅលើដំបូលរួចរាល់ តែជាក់ស្ដែងចុងចម្លើយបានបង់តែចំនួន ៧៥០០០ដុល្លារអាមេរិកប៉ុណ្ណោះ។ ចំពោះការជួសជុលដំបូល និងការជំរះបញ្ជីដែលជាការអះអាងរបស់មេធាវីចុងចម្លើយ ឃើញថាក៏ពុំមានភស្តុតាងណាបញ្ជាក់ទេ ភាគីដើមចោទក៏ធ្លាប់បានចុះទៅពិនិត្យ និងស៊ើបសួរពីការវាយតម្លៃធ្វើដំបូលដែរ ម្យ៉ាងទៀតតុលាការធ្លាប់បានទុកពេលបន្ថែមឱ្យមេធាវីចុងចម្លើយធ្វើការដាក់ភស្តុតាងបញ្ជាក់អំពីការជួលជាងឱ្យជួសជុលដំបូល តែនៅតែពុំមានភស្តុតាង ហេតុនេះបង្ហាញថាចុងចម្លើយមិនបានបំពេញកាតព្វកិច្ចបង់ប្រាក់ឱ្យបានទាន់ពេលវេលា ដែលនេះជាកំហុសរបស់ចុងចម្លើយខ្លួនឯង គប្បីតុលាការពិចារណា។

៣-ដើមចោទទាមទារចុងចម្លើយសងការប្រាក់តាមច្បាប់កំណត់នៃប្រាក់សរុបចំនួន ២១៣,៥៣៥ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃសងរួច និងបានទាមទារប្រាក់ពិន័យចំនួន ២ភាគរយក្នុងមួយខែ នៃប្រាក់សរុបខាងលើ គិតចាប់ពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ រហូតដល់ថ្ងៃសងរួច និងទាមទារឱ្យចុងចម្លើយសងថ្លៃសេវាកម្មមេធាវី និងការខាតបង់នានាចំនួន ២០,០០០$(ពីរម៉ឺនដុល្លាអាមេរិក)។ ឃើញថាតាមកិច្ចសន្យា ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦ មានចែងអំពីការទូទាត់ប្រាក់យឺតយ៉ាវណាមួយនៅក្នុងកម្មវត្ថុត្រូវគិតការប្រាក់ចំនួន ០.៥% ក្នុងមួយសប្ដាហ៍ ដូច្នេះចំនួននេះស្មើនឹងចំនួន ២% ក្នុងមួយខែ ដូចការទាមទាររបស់ដើមចោទខាងលើ។ យោងតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១១ របស់ក្រសួងយុត្តិធម៌ ត្រង់ប្រការ ២ បានកំណត់អត្រាការប្រាក់ដែលព្រមព្រៀងគ្នា មិនអោយលើសចំនួន ១,៥ដង នៃអត្រាការប្រាក់ដែលបានកំណត់ចំនួន១៨%ក្នុង១ឆ្នាំ(ស្មើ២៧%ក្នុងមួយឆ្នាំ) ដូច្នេះការទាមទាររបស់ដើមចោទចំនួន ២%ក្នុងមួយខែ ស្មើនឹង ២៤%ក្នុងមួយឆ្នាំ មានភស្តុតាងគ្រប់គ្រាន់ គប្បីតុលាការពិចារណាសម្រេចផ្អែកតាមកិច្ចសន្យាលេខ ១៦.១៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៦។ តែចំពោះការទាមទារការប្រាក់តាមច្បាប់កំណត់របស់ដើមចោទ និងការទាមទារឱ្យចុងចម្លើយសងថ្លៃសេវាកម្មមេធាវី និងការខាតបង់នានាចំនួន ២០,០០០$(ពីរម៉ឺនដុល្លាអាមេរិក) មិនមានមូលហេតុត្រឹមត្រូវតាមច្បាប់ទេ គប្បីតុលាការមិនពិចារណាសម្រេច។

៤-ចំពោះការទាមទារដើមចោទសុំឱ្យតុលាការប្រកាសសាលក្រមអាចអនុវត្តជាបណ្ដោះអាសន្ន តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទជាការទាមទារប្រាក់ ហើយមានភាពច្បាស់លាស់ និងមានភស្តុតាងគ្រប់គ្រាន់ ដូច្នេះគប្បីប្រកាសថា សាលក្រមអាចអនុវត្តជាបណ្ដោះអាសន្នលើចំណុចទី១-ក បាន។

៥- ប្រាក់ប្រដាប់ក្ដីគប្បីអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១-បង្គាប់ឱ្យចុងចម្លើយ ច បង់ប្រាក់ឱ្យដើមចោទ ក្រុមហ៊ុន ង ដូចខាងក្រោម៖

**ក/ ប្រាក់ចំនួន ២១៣,៥៣៥(ម្ភៃមួយម៉ឺនបីពាន់ប្រាំរយសាមសិបប្រាំ)ដុល្លារអាមេរិក។**

ខ/ ប្រាក់ពិន័យចំនួន **២ភាគរយក្នុង១ខែ** នៃប្រាក់សរុបចំនួន ២១៣,៥៣៥(ម្ភៃមួយម៉ឺនបីពាន់ប្រាំរយសាមសិបប្រាំ)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃសងរួច។

*កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

២-ច្រានចោលការទាមទារការប្រាក់តាមច្បាប់កំណត់ និងប្រាក់ថ្លៃសេវាមេធាវី និងការខាតបង់នានារបស់ដើមចោទ។

៣-សាលក្រមនេះមានអានុភាពអាចអនុវត្តបណ្តោះអាសន្ន ត្រង់សេចក្តីសម្រេចបញ្ចប់ ចំណុចទី១-ក។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា សេង លាង

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៩កើត ខែអាសាឍ ឆ្នាំ កុរ ឯកស័ក ពស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៩

បានឃើញ

**ចៅក្រម**

**សេង_លាង**

**ក្រឡាបញ្ជី**

**ជាម ផលវិច្ឆិកា**